ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

**តាមរយៈ:** លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
**កម្មវត្ថុ:** សិក្ខាសាលា ស្តីពី ប្រសិទ្ធភាព នៃកម្មវិធីជំនួយត្រឡប់ និងសមាហរណកម្មឡើងវិញនៅប្រទេសកម្ពុជា ។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក នៅសណ្ឋាគារកាំបូឌីយ៉ាណា មានបើកសិក្ខាសាលា ស្តីពី ប្រសិទ្ធភាព នៃកម្មវិធីជំនួយត្រឡប់ និងសមាហរណកម្មឡើងវិញនៅប្រទេសកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការអញ្ជើញចូលរួមពីៈ

១. ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
២. លោកជំទាវ ដួង សារុន រដ្ឋលេខាធិការក្រសួងផែនការ
៣. លោកជំទាវ ហោ ម៉ាលីន រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
៤. លោកជំទាវ បណ្ឌិត សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
៥. លោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ
៦. លោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្មអង្គការ IOM
៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ អគ្គលេខាធិការរង គ.ជ.ប.ជ
៨. លោកជំទាវ យូ សុភា អភិបាលរងខេត្តសៀមរាប
៩. លោកជំទាវ កែវ ដាណា អភិបាលរងខេត្តបាត់ដំបង
១០. លោកជំទាវ រស់ សុផានី អភិបាលរងខេត្តបន្ទាយមានជ័យ

តំណាងក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ និងក្រុមការងារបច្ចេកទេសសរុបចំនួន ៤៧ រូប ស្រី ២០ រូប ។

**លោក** Markus Bell អ្នកដឹកនាំសិក្ខាសាលាស្រាវជ្រាវ បានឡើងមានមតិស្វាគមន៍ចំពោះការអញ្ជើញជាគណៈអធិបតីរបស់ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ លោកជំទាវ នាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ ។ លោក MARKUS BELL

បានលើកឡើងអំពីស្ថានភាព នៃការធ្វើចំណាកស្រុកទៅក្រៅប្រទេសរបស់ពលរដ្ឋកម្ពុជាទាំងប្រថុយប្រថានដោយការខ្វះចំណេះដឹង ខ្វះការយល់ដឹង និងការទទួលព័ត៌មានមិនបានគ្រប់គ្រាន់ ។ លោក បានបន្តទៀតថា ពេលពួកគាត់ត្រឡប់មកវិញ គឺភាគច្រើនមានការលំបាកក្នុងការរស់នៅក្នុងសហគមន៍របស់គាត់ ដែលចាំបាច់ត្រូវឲ្យមានការចូលរួមគាំទ្រពីរដ្ឋាភិបាល ក៏ដូចជាអង្គការដៃគូមួយចំនួនផងដែរ ជាពិសេសការវិលត្រឡប់ដោយចាប់បញ្ជូនក្នុងវិបត្តិជំងឺកូវីដ-១៩ កំពុងរីករាលដាល ដែលពួកគាត់ត្រូវការចាំបាច់នូវសេវាគាំទ្រជាច្រើន ដូចជាសេវាសុខភាព មុខរបរ ជំនាញវិជ្ជាជីវៈ ដើម្បីចិញ្ចឹមជីវិត និងគ្រួសាររបស់ពួកគាត់ ។

**លោកស្រី គ្រីស្ទីន ផាភ្វ** ប្រធានបេសកកម្មអង្គការ IOM មានមតិចូលរួមក្នុងសិក្ខាសាលាថា ពិតជាមានសេចក្តីរីករាយសម្រាប់ការជួបជុំគ្នា និងការអញ្ជើញជាគណៈអធិបតីរបស់ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលមានវត្តមានក្នុងពេលនេះ ។ **លោកស្រី** បានលើកឡើងថា ជំងឺកូវីដ-១៩ បានធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសពលរដ្ឋដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ហើយត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់មកវិញរាប់ម៉ឺននាក់ មកទាំងគ្រួសារ មានទាំងកូនតូចៗមកជាមួយផងដែរ គឺជាស្ថានភាពលំបាកសម្រាប់ពួកគាត់ ។ លោកស្រី បានលើកឡើងបន្តថា ដោយមានការយកចិត្តដាក់ពីរដ្ឋាភិបាលបានជ្រើសរើសខេត្តចំនួន៣ គឺខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ សម្រាប់ទទួលពលករវិលត្រឡប់ពីប្រទេសថៃ ។ **លោកស្រី** មានមតិកោតសសើរចំពោះថ្នាក់ដឹកនាំកម្ពុជាគ្រប់លំដាប់ថ្នាក់ ដែលតែងតែយកចិត្តទុកដាក់គិតគូរអំពីសុខទុក្ខរបស់ប្រជាពលរដ្ឋ ជាពិសេស លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ដែលបានចុះផ្ទាល់ជួបជាមួយប្រជាពលរដ្ឋគ្រប់ស្ថានភាព ។ **លោកស្រី** បានបញ្ជាក់បន្ថែមថា ប្រទេសកម្ពុជាក៏ជាប្រទេសទទួលពលករបរទេសមកធ្វើការផងដែរ ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍ និងបើកសិក្ខាសាលា ដោយលោកជំទាវ បានលើកឡើងអំពីកិច្ចសហការក្នុងការអនុវត្តកម្មវិធីរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ រួមមាន០៤ អង្គការ ដូចជាអង្គការ IOM UNICEF UNFPA WHO ដែលយើងបានសហការគ្នាទទួលពលករវិលត្រឡប់ពីក្រៅប្រទេសក្នុងពេលជំងឺកូវីដ-១៩ យើងក៏បានធ្វើការយ៉ាងយកចិត្តទុកដាក់ដោយផ្តោតលើការផ្តល់សេវាជូនពួកគាត់ ។ **លោកជំទាវ** បានបញ្ជាក់ថា ជំងឺកូវីដ-១៩ ពេលនោះគឺបានរាតត្បាតនៅគ្រប់ទីកន្លែង ជាពិសេសនៅកន្លែងធ្វើការរបស់ពួកគាត់ក្នុងប្រទេសគោលដៅ ដែលពួកគាត់ពិបាករស់នៅទីនោះ គាត់ត្រូវត្រឡប់មកវិញដើម្បីជួបជុំក្រុមគ្រួសារក្នុងសហគមន៍របស់គាត់វិញ ប៉ុន្តែក្នុងពេលនោះដោយសារបញ្ហាជំងឺកូវីដ-១៩ កំពុងតែឆ្លងយ៉ាងខ្លាំង គឺយើងត្រូវផ្តល់សេវាគ្រប់បែបយ៉ាង ជាពិសេសការថែទាំសុខភាពរបស់ពួកគាត់ ដោយសារពួកគាត់ត្រឡប់មកវិញមិនមែនតាមច្រកផ្លូវការទេ ជាពិសេសប្រទេសថៃដែលជាប្រទេសមានទេសន្តរប្រវេសន៍ច្រើនជាងគេ បានប្រកាសបិទព្រំដែនធ្វើឲ្យពួកគាត់ត្រូវវិលត្រឡប់មកវិញតាមច្រកមិនផ្លូវការ គ្មានឯកសារគ្រប់គ្រាន់ គ្មានការទទួល និងគ្មានការទំនាក់ទំនងផ្លូវការណាមួយដែលធ្វើឲ្យពួកគាត់មានភាពកក់ក្តៅ ពេលពួកគាត់ត្រឡប់មកវិញភាគច្រើន គឺគាត់មកដៃទទេ ឬមានឥវ៉ាន់បន្តិចបន្តួច និងមានកូនតូចមកជាមួយប៉ុណ្ណោះអ្នកខ្លះមកដល់ទាំងយប់អាធ្រាត្រ ថ្ងៃត្រង់ មេឃភ្លៀង និងទឹកជំនន់ជាដើម គឺពិតជាពិបាកណាស់ អ្វីដែលយើងត្រូវធ្វើចាំបាច់សម្រាប់ការផ្តល់សេវា គឺការធ្វើសមាហរណកម្មទៅតាមសហគមន៍ ហើយអ្វីដែលជាបញ្ហាលំបាក

គឺការដោះស្រាយចំពោះពួកគាត់មួយចំនួនដែលគ្មានផ្ទះសម្បែងនៅក្នុងសហគមន៍របស់គាត់ ដែលគាត់គិតថាលែងត្រឡប់មកវិញ ដូច្នេះយើងត្រូវមើលថែទាំ ផ្តល់សេវាសុខភាព ការបណ្តុះបណ្តាលវិជ្ជាជីវៈ រកការងារឲ្យគាត់ធ្វើ ឬបង្កើតការងារសម្រាប់គាត់សម្រាប់ចិញ្ចឹមជីវិតជាបណ្តោះអាសន្ន ដោយយើងមិនអាចដឹងថាជំងឺកូវីដ-១៩ ចប់នៅថ្ងៃណាឡើយ ហើយក៏មិនដឹងថាពួកគាត់ត្រូវរស់នៅក្នុងសហគមន៍ ឬត្រូវចាកចេញទៅវិញនោះទេ ។ **លោកជំទាវ** បានមានប្រសាសន៍បន្ថែមថា យើងទាំងអស់គ្នាបានសហការជួយពួកគាត់គ្រប់ទីកន្លែង ដោយមិនប្រកាន់ថាជាការងាររបស់ក្រសួង ស្ថាប័នណាមួយឡើយ ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ ថ្នាក់មូលដ្ឋាន អាជ្ញាធរ សមត្ថកិច្ចតាមបន្ទាត់ព្រំដែនជាដើមដោយពួកគាត់ធ្វើការងារនេះទាំងយប់ទាំងថ្ងៃ និងភ្លៀងខ្យល់ ។ **លោកជំទាវ** ក៏បានលើកឡើងថា ទន្ទឹមនឹងស្ថានភាពលំបាកនេះ ក៏មានពលរដ្ឋមួយចំនួនសម្រេចចិត្តត្រឡប់ទៅវិញ បានធ្វើការឆ្លងដែនដោយប្រថុយប្រថានទាំងដែលប្រទេសទទួលមិនទាន់បើកច្រកព្រំដែន ឬស្វាគមន៍ពួកគាត់នៅឡើយ ហើយពួកគាត់ត្រូវប្រឈមការគ្រោះថ្នាក់ និងការខាតបង់ជាច្រើន និងត្រូវបានមេខ្យល់ព្យាយាមកេងប្រវ័ញ្ចផលប្រយោជន៍ពីពួកគាត់បន្ថែមទៀត ។ **លោកជំទាវ** លើកឡើងបន្តថា យើងបានពិភាក្សាគ្នាជាមួយអង្គការ IOM ត្រូវធ្វើ Survey ឡើងវិញពាក់ព័ន្ធបញ្ហាទាំងនេះ តើយើងត្រូវធ្វើអ្វីបន្ថែមទៀត? យើងនៅខ្វះអ្វី? យើងមានអ្វីខ្លះ? បើមានតើមានប្រសិទ្ធភាពប៉ុណ្ណា? គណៈកម្មាធិការជាតិមិនបានយកការងាររបស់ក្រសួង ស្ថាប័នណាមកធ្វើទេ ពីព្រោះពេលបញ្ហាគឺគេសួរទៅរដ្ឋាភិបាលទាំងមូល គឺគេមិនសួរទៅក្រសួង ស្ថាប័នណាទេ ដូច្នេះក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន ២២ ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្តទាំង២៥ រួមគ្នាទទួលខុសត្រូវ ។ **លោកជំទាវ** បានមានប្រសាសន៍ពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវបន្ថែម គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការបំពេញភាពខ្វះចន្លោះសម្រាប់ជាមូលដ្ឋានដែលអាចឲ្យក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធអនុវត្តឲ្យមានប្រសិទ្ធភាព ហើយយើងនឹងធ្វើការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់ដើម្បីរកឲ្យឃើញនូវចំណុចខ្វះខាត តើអ្វីទៅជាចំណុចខ្វះខាត? តើត្រូវធ្វើដោយរបៀបណា? តាមវិធីសាស្ត្រអ្វី? លោកជំទាវ មានប្រសាសន៍បញ្ជាក់ថា យើងបានរួមគ្នាធ្វើការងារនេះយ៉ាងសកម្ម គ្រប់សកម្មភាពដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ប៉ុន្តែលទ្ធផលដែលកម្ពុជាទទួលបានមកវិញ គឺការផ្តល់ចំណាត់ថ្នាក់មិនល្អ យើងបានត្រឹមតែសោកស្តាយ សួរថាតើមានក្រសួង ស្ថាប័នណាខ្លះហ៊ានចេញមុខទទួលថាលទ្ធផលទាំងនេះ គឺមកពីក្រសួង ស្ថាប័ននេះ/នោះ? ដូច្នេះនេះគឺជារឿងដែលយើងទាំងអស់គ្នាត្រូវរួមចំណែកធ្វើការងារនេះទាំងអស់គ្នា មិនមែនមានក្រសួង ស្ថាប័នណាមួយអាចធ្វើការងារនេះបានតែម្នាក់ឯងទេ យើងមិនអាចចង្អុលដាក់គ្នា ឬចង្អុលមកគណៈកម្មាធិការជាតិនោះទេ គណៈកម្មាធិការជាតិ គ.ជ.ប.ជ គឺយើងទាំងអស់គ្នាដែលមាន ២២ ក្រសួង ស្ថាប័ន ទទួលខុសត្រូវទាំងអស់គ្នា ហើយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គឺជាអ្នកសម្របសម្រួល ប្រមូលទិន្នន័យ បូកសរុបទិន្នន័យ រួចបញ្ជូនទិន្នន័យទាំងអស់នោះត្រឡប់ទៅវិញ និងរៀបចំជារបាយការណ៍សម្រាប់ថ្នាក់ដឹកនាំដើម្បីពិនិត្យ ។ **លោកជំទាវ** មានប្រសាសន៍ពាក់ព័ន្ធនឹងលទ្ធផល នៃការសិក្សាស្រាវជ្រាវនេះ សូមឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធមេត្តាយកទៅប្រើប្រាស់ត្រង់ចំណុចខ្វះខាត ដើម្បីជួយដល់ពលរដ្ឋយើងដែលបានវិលត្រឡប់មកពីក្រៅប្រទេស ជាពិសេសអ្នកដែលគ្មានលទ្ធភាពចិញ្ចឹមជីវិត ទីទាល់ក្រ ត្រូវគិតថានេះគឺជាការងាររួមគ្នា យើងនឹងធ្វើទៅតាមផែនការដែលបានគ្រោងទុក ។ **លោកជំទាវ** បានមានប្រសាសន៍ជូនពរ ឯកឧត្តម លោកជំទាវ

លោក លោកស្រីទាំងអស់ដែលបានចូលរួមក្នុងកម្មវិធីសិក្ខាសាលានាថ្ងៃនេះទទួលបានជោគជ័យ និងចៀសផុតពីជំងឺគ្រប់យ៉ាងទាំងអស់គ្នា ។ លោកជំទាវ មានប្រសាសន៍ប្រកាសបើកសិក្ខាសាលាចាប់ពីពេលនេះតទៅ ។

- **ការធ្វើបទបង្ហាញរបស់ក្រុមសិក្សាស្រាវជ្រាវ**

**លោកស្រី ឈឿន ស្រីនាង** អ្នកស្រាវជ្រាវការសិក្សា បានឡើងធ្វើបទបង្ហាញ ស្ដីពី

- កម្មវត្ថុ នៃការសិក្សាស្រាវជ្រាវ
- វិធីសាស្ត្រស្រាវជ្រាវ
- ដែនកំណត់ នៃការសិក្សា
- លទ្ធផលសំខាន់ៗ ផ្នែកសង្គម
    - ការមានលំនៅឋាន និងស្តង់ដារ
    - ការទទួលបានការអប់រំ
    - ការទទួលបានយុត្តិធម៌
    - ការទទួលបានសេវាថែទាំសុខភាព និងគុណភាព
    - ប័ណ្ណក្រីក្រ
    - ការទទួលបានឯកសារ
    - មូលហេតុ នៃការធ្វើចំណាកស្រុក
    - ជំនួយកំឡុងពេលត្រឡប់កវិញ

**លោក** Todd Hunkin អ្នកឯកទេសស្រាវជ្រាវ ឡើងធ្វើបទបង្ហាញ ស្ដីពី

- លទ្ធផលសំខាន់ៗ ផ្នែកចិត្តសង្គម
    - ការជួបជុំក្នុងសកម្មភាពសង្គម
    - បណ្តាញគាំទ្រ
    - អារម្មណ៍ចំពោះសហគមន៍ និងសុវត្ថិភាព
    - ភាពតានតឹង និងការរើសអើង
    - ផលវិបាកផ្លូវចិត្ត
- លទ្ធផលសំខាន់ ផ្នែកសេដ្ឋកិច្ច
    - ផលប៉ះពាល់ពីជំងឺកូវីដ-១៩
    - ការពេញចិត្តនឹងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន
    - ការកាត់បន្ថយម្ហូបអាហារ
    - ការខ្ចីបុល
    - ការទទួលបានឱកាស
    - ការងារ
- ពិន្ទុសរុប និងពិន្ទុតាមផ្នែកនីមួយៗ

❖ **សំនួរ**

១. លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

២. លោកជំទាវ បណ្ឌិត សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៣. លោក ថា សារ៉ាវុធ តំណាងអង្គការ UNDP

❖ **ចម្លើយ**

១. លោកស្រី ឈឿន ស្រីនាង អ្នកស្រាវជ្រាវគុណវិស័យ

២. លោក Todd Hunkin អ្នកឯកទេសស្រាវជ្រាវ

❖ **សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

**លោក** Markus Bell អ្នកដឹកនាំការសិក្សាស្រាវជ្រាវ

បានធ្វើបទបង្ហាញ ស្ដីពី សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

- សេចក្ដីសន្និដ្ឋាន
    - ការអនុវត្តទូទៅ
    - ការស្រាវជ្រាវនាពេលអនាគត
- អនុសាសន៍

❖ **ការពិភាក្សាជាក្រុម**

កម្មវិធីសិក្ខាសាលាបានធ្វើការបែងចែកក្រុមពិភាក្សាជា ៤ ក្រុម ដើម្បីធ្វើការពិភាក្សារកចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈម ។

កម្មវិធីសិក្ខាសាលាបានបញ្ចប់នៅវេលាម៉ោង ១២ និង ២០ នាទី ថ្ងៃខែឆ្នាំដដែល ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃសុក្រ ៧រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ទោ. សៅ ស៊ីនួន

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ សុក្រ ៧ កើត ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០២២

**អគ្គលេខាធិការ**

2

ឧត្តមសេនីយ៍ឯកវេជ្ជ. ប៊ុណ្ណ សំខាន់

ឯកភាព

05/09/22

ជូ_ប៊ុនអេង